ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី ៣៣៣*៧៧

លេខ: ២២៣

ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០២ **នាមនាមប្រជារាស្ត្រខ្មែរ**

**សាលដីកា** **តុលាការកំពូល**

លេខ: ០៣ បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី១២ ខែមករា ឆ្នាំ២០០៤

ចុះថ្ងៃទី១២ ខែ មករា ឆ្នាំ២០០៤ ដោយមានសមាសភាពដូចតទៅ :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ឃឹម** | **ប៉ុណ្ណ** | ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ |
| ២-លោក | ស៊ិន | ឌឹម | ជាចៅក្រម |
| ៣-លោក | ជីវ | កេង | ជាចៅក្រម |
| ៤-លោក | ប្រាក់ | គីមសាន | ជាចៅក្រមរបាយការណ៍ |
| ៥-លោក | ឈឹម | ស៊ីផល | ជាចៅក្រម |
| ៦-លោក | សោម | សិរីវឌ្ឍ | ជាចៅក្រម |
| ៧-លោក | យស់ | សូខឿន | ជាចៅក្រម |
| ៨-លោក | ប៉ែន | សារឿន | ជាចៅក្រម |
| ៩-លោក | គង់ | ភីរុន | ជាចៅក្រម |

ក្រឡាបញ្ជី

កញ្ញា **ហុក សុខគុល**

តំណាងមហាអយ្យការ

លោក **ឈួន ចាន់ថា** ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខលើកទី២ពីសាលដីការដ្ឋប្បវេណីលេខ ៩០ "គ" ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០១ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៣៦ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០១របស់សាលាឧទ្ធរណ៍រវាង :

ដើមចោទឈ្មោះ **អ៊ុច គីមសាន្ត** (ម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ មុខរបរយោធា ទីលំនៅសព្វថ្ងៃភូមិចំពុះក្អែក ឃុំព្រែកថ្មី ស្រុកកៀនស្វាយ ខេត្តកណ្តាល ។ ឪពុកឈ្មោះអ៊ុច សំផន (ស) ម្តាយឈ្មោះអ៊ុង យ៉ន(ស) ប្រពន្ធឈ្មោះជា ឈុនឡាំង មានកូន២នាក់ ។

មានមេធាវី លោក ទូត លុច ។

ចុងចំលើយឈ្មោះ **ជា ឈុនឡាំង** (ចុងបណ្តឹងសាទុក្ខ) ភេទស្រី អាយុ៣២ ជាតិខ្មែរ

មុខរបរលក់ផ្លែឈើ ទីលំនៅសព្វថ្ងៃភូមិចំពុះក្អែក ឃុំព្រែកថ្មី ស្រុកកៀនស្វាយ ខេត្តកណ្តាល ។ ឪពុកឈ្មោះ ឡេង ប៊ុនហ៊ាង (ស) ម្តាយឈ្មោះជា សែ (រ) ប្តីឈ្មោះអ៊ុច គីមសាន មានកូន០២នាក់ ។

មានមេធាវីលោក ស៊ឹម ស៊ីថាន ។

**កម្មវត្ថុបណ្តឹង** : ប្តឹងលែងលះប្រពន្ធ

បានឃើញបណ្តឹងសាទុក្ខលើកទី២លេខ៤០៨ ចុះថ្ងៃទី២៦ ខែវិច្ឆិកាឆ្នាំ២០០១ របស់ឈ្មោះអ៊ុចគីមសាន្ត ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ៩០"គ"ចុះថ្ងៃទី២០ខែវិច្ឆិកា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ២២៣ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០២ របស់តុលាការកំពូល។

តាមពាក្យបណ្តឹងចុះថ្ងៃទី៤-៨-១៩៩៨របស់លោកអ៊ុចគីមសាន្ត ប្តឹងលែងលះប្រពន្ធឈ្មោះជាឈុនឡាំង ដោយហេតុថា ប្រពន្ធខ្លួនដេរប្រមាថម៉ាក់ងាយ និងដកហូតម៉ូតូពីខ្លួន ខ្លួនអស់មនោសញ្ចេតនាក្នុងការរួមរស់ជាមួយគ្នាទៀតហើយ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ៦៤"ក" ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់តុលាការខេត្ត ខេត្តកណ្តាល ដែលបានសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងចុះថ្ងៃទី០៤-៨-១៩៩៨ របស់ដើមចោទ ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-បង្គាប់ឱ្យឈ្មោះអ៊ុច គីមសាន្ត និងនាងជា ឈុនឡាំង ដាច់សមគ្គសង្វាសពីគ្នា ចាប់តាំងពីថ្ងៃនេះតទៅ តាមបញ្ញត្តិមាត្រា ៣៩ ចំណុច២នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ។

៣-បង្គាប់ឱ្យឈ្មោះជា ឈុនឡាំង ស្ថិតនៅក្នុងភាពម៉េម៉ាយចំនួន៣០០ថ្ងៃ គិតចាប់ពីថ្ងៃនេះតទៅ តាមបញ្ញត្តិមាត្រា៩ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ។

៤-កូនពីរនាក់ ទីមួយឈ្មោះអ៊ុច ស្រីរ័ត្ន ភេទស្រី កើតឆ្នាំ១៩៩០ កូនទី២ឈ្មោះ អ៊ុច ចន្ថា ភេទប្រុស កើតឆ្នាំ១៩៩៣ ត្រូវប្រគល់ឱ្យនាងជា ឈុនឡាំង"ចុងចំលើយ"គ្រប់គ្រងថែរក្សា តែឱ្យឈ្មោះអ៊ុច-គីមសាន្ត ចេញអាហារកិច្ចចិញ្ចឹមកូនទាំង០២នាក់នេះ តាមរបបរដ្ឋកំណត់ជារៀងរាល់ខែចាប់តាំងពីខែវិច្ឆិកា ឆ្នាំ១៩៩៨ និងឧបត្ថម្ភបន្ថែមទៀត តាមលទ្ធភាព និងតាមការព្រមព្រៀងរបស់ដើមចោទ ។មាតាបិតាត្រូវមានសិទ្ធិ និងករណីយកិច្ចអប់រំ ថែរក្សាចិញ្ចឹមកូន តាមបញ្ញត្តិមាត្រា៧២,៧៣,និង៧៤ នៃច្បាប់អាពាហ៍ពិពាហ៍និងគ្រួសារ

៥-ទ្រព្យសម្បត្តិរួមដែលមានម៉ូតូសេ១០០មួយគ្រឿងតំលៃ១.០០០ដុល្លាអាមេរិកទូរទស្សន៍ពណ៌មួយគ្រឿងតំលៃ២២០ដុល្លាអាមេរិក មាសប្រាក់នៅនឹងខ្លួនចុងចំលើយ ចំណែកផ្ទះដែលយកទៅធ្វើរោងបាយជាមួយផ្ទះម្តាយ ត្រូវប្រគល់ឱ្យទៅនាង ជាឈុនឡាំង ទុកសំរាប់ចិញ្ចឹមកូនតទៅតាមការព្រមព្រៀងរបស់ដើមចោទ តាមបញ្ញត្តិមាត្រា៧០នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ។

៦-ទ្រព្យសម្បត្តិដោយឡែករបស់ដើមចោទ ដីលំនៅដ្ឋានមួយកន្លែងមានទំហំ១៥៩៩ម៉ែត្រការេ ដែលមានព្រំប្រទល់ខាងកើតទល់នឹងដីអៀង មិញ ខាងលិចទល់ផ្លូវ ខាងជើងទល់ដីឈួ គួយ និងខាងត្បូងទល់

ដីស៊ីន អៀវ ស្ថិតនៅក្នុងភូមិចំពុះក្អែក ឃុំព្រែកថ្មី ស្រុកកៀនស្វាយ ខេត្តកណ្តាល ត្រូវប្រគល់ឱ្យទៅឈ្មោះ អ៊ុច គីមសាន្ត "ដើមចោទ" គ្រប់គ្រងប្រើប្រាស់ជាកម្មសិទ្ធិផ្ទាល់ ចាប់តាំងពីថ្ងៃនេះតទៅ តាមបញ្ញត្តិមាត្រា៧០ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ។

៧-ទុកសិទ្ធិឱ្យដើមចោទទៅសួរសុខទុក្ខកូនបានតាមបញ្ញត្តិមាត្រា៧៥ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ។

៨-សំរេចទទួលស្គាល់តាមផ្លូវច្បាប់ ការសុំបដិសេធ ប័ណ្ណសំគាល់សិទ្ធិប្រើប្រាស់ដីធ្លីលេខ G១២០៧៥១ ចុះថ្ងៃទី២៧-២-៩២ដែលដាក់ជាកម្មសិទ្ធិរួមប្តីប្រពន្ធចោលជាអាសាបង់ តាមសំណូមពរដើមចោទ ចាប់តាំងពីថ្ងៃនេះតទៅ ។

៩-បង្គាប់ឱ្យឈ្មោះអ៊ុច គីមសាន ទៅចុះបញ្ជីសំគាល់អចលនទ្រព្យដីលំនៅដ្ឋានទំហំ ១៥៥៩ ម៉ែត្រការេ ថាជាទ្រព្យសម្បត្តិដោយឡែករបស់ដើមចោទ នៅនាយកដ្ឋានសុរិយោដី ។

១០-បង្គាប់ឈ្មោះអ៊ុច គីមសាន្ត បង់ប្រាក់ប្រដាប់ក្តីសរុប៧.០០០៛ ក្នុងនោះពន្ធហ្វ៊ីង និងពន្ធចុះបញ្ជីក្តី១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០៛ និងពន្ធលើការស៊ើបអង្កេត៥.០០០៛ ប្រាក់នេះដើមចោទបានបង់រួចហើយ ។

១១-សាលក្រមនេះជំនុំជំរះ ជាសាធារណៈ កំបាំងមុខចុងចំលើយ ចំពោះមុខដើមចោទបើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី៦ ខែមករា ឆ្នាំ១៩៩៩ របស់អ្នកស្រីជា ឈុនឡាំង ប្តឹងមិនសុខចិត្ត នឹងសាលក្រមរដ្ឋប្បវេណីលេខ៦៤"ក" ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់តុលាការខេត្តកណ្តាល ត្រង់ចំណុចនៃសាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៦៧០ ចុះថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី-៦-០១-១៩៩៩ របស់ឈ្មោះ ជា ឈុនឡាំង ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-តំកល់សាលក្រមរដ្ឋប្បវេណីលេ៦៤"ក" ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់តុលាការខេត្តកណ្តាល ទុកជាបានការដដែល លើកលែងតែចំណុចទី៦ នៃសេចក្តីសំរេចដែលត្រូវបដិសេធចោល ចំណុចក្រៅពីនេះទុកជាបានការដដែល ។

៣-សំរេចប្រគល់ដីលំនៅដ្ឋានស្ថិតនៅភូមិចំពុះក្អែក ឃុំព្រែកថ្មី ស្រុកកៀនស្វាយ ខេត្តកណ្តាល ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ G១២-០៧៥១ ចុះថ្ងៃទី២៧-០២-៩២ ឱ្យទៅចុងចំលើយឈ្មោះជាឈុនឡាំង កាន់កាប់ជាកម្មសិទ្ធិតទៅ តាមមាត្រា៧០នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ ។

៤-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០៛ គឺពន្ធចុះបញ្ជីក្តី និង ពន្ធហ្វ៊ីង

២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០៛ ចំណាយលើការប្រគល់ដីកាកោះ៥.០០០៛ និងលើអាជ្ញាធរតុលាការ៥.០០០៛ សរុប ១៣.០០០៛ ។

៥-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ៣៨៤ ចុះថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ១៩៩៩ របស់ឈ្មោះ អ៊ុច គីមសាន្ត ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណី ៦៧០ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចទី៣ នៃសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៥៦ ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ២០០១ របស់តុលាការកំពូលដែលបានសំរេចដូចតទៅ :

១-ទទួលបណ្តឹងសាទុក្ខលេខ៣៨៤ ចុះថ្ងៃទី១៧-៩-១៩៩៩ របស់លោកអ៊ុច គីមសាន្ត ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ខ្លះ ។

២-កំកល់សាលដីការដ្ឋប្បវេណីលេខ៦៧០ ចុះថ្ងៃទី១៣-៩-១៩៩៩ របស់សាលាឧទ្ធរណ៍ទុកជាបានការ លើកលែងតែចំណុចទី២ ត្រង់ឃ្លាចុងក្រោយដែលថា លើកលែងតែចំណុចទី៦ នៃសេចក្តីសំរេចដែលត្រូវបដិសេធចោល ចំណុចក្រៅពីនេះទុកជាបានការដដែល និងចំណុចទី៣ ដែលត្រូវទុកជាមោឃៈ ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ១២៣ ចុះថ្ងៃទី១៥-៣-២០០០ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ត្រង់ចំណុចដែលត្រូវទុកជាមោឃៈខាងលើ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីដែលលោកអ៊ុចគីមសាន្តបានបង់ទុកនៅតុលាការកំពូលចំនួន១៩០០០៛ គឺ :

-ពន្ធចុះបញ្ជីក្តី នឹង ពន្ធប្តឹងចំនួន៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០៛ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់.

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប១៩.០០០៛ ហើយគំរូវឱ្យអ្នកស្រីជាឈុនឡាំងសងប្រាក់ចំនួន១៩.០០០៛ នេះទៅដើមចោទវិញ ។

៥-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០១ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៩០"គ" ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ដែលបានសំរេចដូចតទៅ :

១-ទទួលជំនុំជំរះសំណុំរឿងរដ្ឋប្បវេណីលេខ ៣៦ ចុះថ្ងៃទី ២១-០៦-២០០១ របស់សាលាឧទ្ធរណ៍តាមអំណាចសាលដីការដ្ឋប្បវេណីលេខ ៥៦ ចុះថ្ងៃទី១៩-៤-២០០១ របស់តុលាការកំពូល ។

២-ដីស្ថិតនៅភូមិចំពុះក្អែកឃុំព្រែកថ្មី ស្រុកកៀនស្វាយ ខេត្តកណ្តាលដែលមានប័ណ្ណសំគាល់សិទ្ធិប្រើប្រាស់ដីធ្លីលេខ ០១២-០៧៥១ ចុះថ្ងៃទី២៧-០២-១៩៩២ បែងចែកជាបីចំណែក គឺ :

- ១/៣ បានទៅឈ្មោះអ៊ុច គីមសាន្ត និង២/៣ បានទៅនាង ជាឈុនឡាំង ចាប់ពីពេលសាលដីកានេះ ចូលជាស្ថាពរ ។

៣-សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលើកទី២លេខ៤០៨ ចុះថ្ងៃទី២៦ ខែវិច្ឆិកាឆ្នាំ២០០១ របស់ឈ្មោះអ៊ុចគីមសាន្ត ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ៩០"គ"ចុះថ្ងៃទី២០ខែវិច្ឆិកា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីការបៀបលេខ១៩៥ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៣ របស់តុលាការកំពូល ដែលមានខ្លឹមសារនៃសេចក្តីសំរេច ដូចតទៅ :

១-ចាត់របៀបឱ្យចៅក្រមប្រឹក្សាចុះពិនិត្យដល់ទីតាំងដីទំនាស់ និងគូសប្លង់បង្ហាញទីតាំងឱ្យបានច្បាស់លាស់ ហើយក្នុងករណីចាំបាច់ ត្រូវធ្វើការស៊ើបអង្កេតបន្ថែម ។

២-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៣ ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : សាលដីកាលេខ៩០ "គ" ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ហើយ ។ សូមក្រុមប្រឹក្សាជំនុំជំរះសំរេចតាមច្បាប់ ។

បានស្តាប់ចំលើយរបស់ឈ្មោះ អ៊ុច គីមសាន្ត នៅពេលជំនុំជំរះថា : ក្នុងការលែងលះប្តីប្រពន្ធនេះ ខ្លួនចុះចេញតែខ្លួន ដោយប្រគល់ទ្រព្យសម្បត្តិរួមអោយទៅប្រពន្ធ និងកូនទាំងអស់ លើកលែងតែដីមួយកន្លែងដែលមានក្បាល ១០ម គុណ ១០០ម ដែលខ្លួនសុំយកពាក់កណ្តាល៥ម និង៥មទៀតអោយទៅកូន លើកលែងដី១០ម$^2$ត្រង់កន្លែងផ្នូរម្តាយខ្លួន គឺខ្លួនទុកជាទីសក្ការៈបូជា ព្រោះដីនេះជាដីកេរ្តិ៍ម្តាយរបស់ខ្លួន ចែកអោយខ្លួន ឯបងស្រីខ្លួនគឺគាត់ចែកផ្ទះនៅលើដីនេះអោយគាត់ ហើយខ្លួននិងប្រពន្ធខ្លួនបានទិញផ្ទះនោះពីបងស្រីខ្លួនយក ហើយផ្ទះនោះបានរុះយកទៅធ្វើផ្ទះបាយនៅខាងផ្ទះម្តាយក្មេកខ្លួនអស់ហើយ ។

បានស្តាប់ចំលើយរបស់ឈ្មោះ ជា ជីវ ទទួលសិទ្ធិពីបងស្រី ជា ឈុនឡាំង នៅពេលជំនុំជំរះថា : ម្តាយខ្លួនជាអ្នកយកលុយមួយតំឡឹងកន្លះមាសនេះទៅទិញដី ពីបងស្រីលោកអ៊ុច គីមសាន្ត. មិនមែនទិញតែផ្ទះទេ ហើយបើគាត់និយាយពីកេរ្តិ៍នោះគឺខុសហើយ រយៈពេលប្រាំមួយប្រាំពីរឆ្នាំនេះ លោកអ៊ុច គីមសាន្ត បានចុះចេញពីផ្ទះដោយមិនបានចិញ្ចឹមកូនមួយរៀលណាទេ ក្នុងនាមគាត់ជាឪពុក មានតែបងស្រីខ្លួនទេ ជាអ្នកចិញ្ចឹមកូនពីរនាក់នោះ។ ខ្លួនសំណូមពរ សុំអោយតុលាការផ្តល់យុត្តិធម៌ដោយប្រគល់ដីនោះអោយទៅកូនទាំងអស់ បើប្រពន្ធមិនបានចំនែក ប្តីក៏មិនបានចំនែកដែរ គឺដីនោះត្រូវប្រគល់អោយកូនទាំងអស់ ។

បានស្តាប់ចំលើយបន្ថែមរបស់លោកអ៊ុច គឹមសាន្ត នៅពេលជំនុំជំរះថា :ប្អូននេះថា ខ្លួនមិនបានចិញ្ចឹមកូន ចុះអាហារកិច្ចរាល់ខែ ដែលនាងជា ឈុនឡាំង ទៅបើកនោះជាអ្វី មិនមែនលុយខ្លួនចិញ្ចឹមកូនទេរី។ ខ្លួននៅតែសុំយកដីនោះពាក់កណ្តាល និង ពាក់កណ្តាលទៀតខ្លួនប្រគល់អោយកូន ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកទូត លុច ជាមេធាវីការពារឱ្យដើមចោទ នៅពេលសវនាការថា : កម្មវត្ថុបណ្តឹងគឺទាក់ទងទៅនឹងដីកេរ្តិ៍មួយកន្លែង ដែលម្តាយលោកអ៊ុច គឹមសាន្ត បានចែកអោយលោក និងចែកផ្ទះអោយបងស្រីលោកអ៊ុច គឹមសាន្ត ។ នៅឆ្នាំ១៩៨៩ កូនក្តីខ្លួនបានរៀបការជាមួយអ្នកស្រីជា ឈុនឡាំង ក្រោយមកដោយរស់នៅមិនចុះសំរុងគ្នា ក៏បានលែងលះគ្នា ដោយប្រគល់ទ្រព្យសម្បត្តិរួមទាំងអស់អោយទៅប្រពន្ធ។ ហើយក្នុងការអះអាងថា អ្នកស្រីបានទិញដីនិងផ្ទះនោះ ពុំមានភស្តុតាងណាសំរាប់យកមកបញ្ជាក់នោះទេ ហើយចំពោះសាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីនោះក៏មានចំណុចខុសឆ្គងដែរ ។ កូនក្តីខ្លួនសុំសំណូមពរគ្រប់គ្រងដីពាក់កណ្តាល តាមគំនូសប្លង់ចុះអង្កេតរបស់តុលាការ គឺមួយផ្នែកខាងត្បូង និង១ផ្នែកខាងជើងចែកអោយកូនដោយដកទុក១០ម$^{2}$ ត្រង់កន្លែងផ្នូរម្តាយទុកជាទីសក្ការៈបូជា ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់ឈ្មោះស៊ឹម ស៊ីថាន ជាមេធាវីការពារឱ្យចុងចំលើយនាពេលសវនាការថា ដីនេះគឺទ្រព្យសម្បត្តិរួមរវាងប្តីប្រពន្ធទាំងពីរនាក់ ដោយផ្អែកលើបង្កាន់ដៃ ។ បើដីនេះពាក់កណ្តាលជាចំណែកឱ្យលោកអ៊ុច គឹមសាន្ត និងពាក់កណ្តាលទៀតអោយទៅកូន ហើយអ្នកស្រីជា ឈុនឡាំង គ្មានចំណែកនោះជាការអយុត្តិធម៌ណាស់ ក្នុងនាមនាងជាស្ត្រីមេមាយដែលខ្លួនរកស៊ីចិញ្ចឹមកូន នាងមានទុក្ខសោកច្រើនណាស់ សូមតុលាការអនុគ្រោះដល់ស្ត្រីមេមាយផង ហើយមួយវិញទៀតបើថា ដីទំនាស់នោះវាជាចំនែកតិចតួចណាស់ ខ្លួនសុំសំណូមពរ សុំប្រគល់អោយទៅកូនទាំងអស់ទៅ ដើម្បីអោយកូនរស់នៅ ហើយគោរពបូជាផ្នូរលោកយាយទៅចៅក៏អាចគោរពបូជាបានដែរ ។ សំណូមពរចុងក្រោយសូមតំកល់សាលដីកាលេខ៦៧០ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់លោក ទូត លុច នៅពេលជំនុំជំរះថា : ខ្លួនគ្រាន់តែសុំលើកឡើងបីចំណុចតបទៅ និង លោកមេធាវីវិញថា :

ទី១ :សូមពិនិត្យពីស្ថានភាពអ្នកក្រ និងស្ថានភាពអ្នកមានលោកអ៊ុច គឹមសាន្ត គាត់ទីទាល់ក្រជួលផ្ទះគេនៅទេសព្វថ្ងៃនេះ ។

ទី២ :លោកថាប្រគល់អោយទៅកូនក៏អាចគោរពបូជាបាន ចុះក្នុងនាមគាត់ជាឪពុកនោះ តើគិតយ៉ាងណា គាត់មិនរឹតតែត្រូវគោរពបូជាជាងចៅទៅទៀត ។

ទី៣ :លោកថាអ្នកស្រីជាស្ត្រីមេមាយ តើសព្វថ្ងៃនេះគាត់មេមាយ រឺ ក៏មានប្តីហើយ ? ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចំលើយរបស់គូភាគី និងសេចក្តីសន្និដ្ឋានរបស់មេធាវីគូភាគី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលើកទី២លេខ៤០៨ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០១ របស់លោក អ៊ុច គីមសាន្ត ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះដល់អង្គសេចក្តីបានតាម មាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី និងមាត្រា២២៦ នៃច្បាប់ស្តីពីនីតិវិធី ព្រហ្មទណ្ឌដែលមានអានុភាពផងដែរ ក្នុងរឿងរដ្ឋប្បវេណី ។

- យល់ឃើញថា ការលើកឡើងរបស់លោកអ៊ុច គីមសាន្ត ក្នុងសារណាចុះថ្ងៃទី១៦ខែសីហាឆ្នាំ២០០២ ថាដីសង់លំនៅដ្ឋាន ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់លេខG.120751 ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ១៩៩២ជា ទ្រព្យដោយឡែក នោះគឺជាការពុំត្រឹមត្រូវឡើយ ពីព្រោះថា នៅលើប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ខាងលើនេះមានបញ្ជាក់ថា ជាទ្រព្យសម្បត្តិរួមប្តី-ប្រពន្ធ ដែលគប្បីបែងចែកតាមមាត្រា៧០ នៃច្បាប់ស្តីពីអាពាហ៍ ពិពាហ៍ និងគ្រួសារ ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចប្រគល់ដីទំនាស់ទំហំ ½ឱ្យដើមចោទ និង ប្រគល់ដី ឱ្យចុងចម្លើយ ដោយអាងហេតុថា អ្នកស្រីជា ឈុនឡាំង ទទួលបន្ទុកចិញ្ចឹមកូន ហើយអាហារកិច្ចតាមរបប រដ្ឋកំណត់ពុំគ្រប់គ្រាន់នោះ គឺជាការពុំត្រឹមត្រូវទេ ពីព្រោះថា ទ្រព្យសម្បត្តិរួមទាំងអស់ក្រៅពីដីនេះ តុលាការបាន ប្រគល់ឱ្យចុងចម្លើយអស់ហើយ ដោយមានទាំងអាហារកិច្ចផង ។ ម្យ៉ាងទៀតទំហំដី½នេះ ពុំអាចឱ្យដើមចោទ សង់លំនៅដ្ឋានបានសមរម្យទេ ហើយការបែងចែកនេះ អាចមានការប៉ះពាល់ទៅដល់ទីតាំងផ្លូវសពម្តាយរបស់ ដើមចោទផងដែរ ។

- យល់ឃើញថា ដើម្បីឱ្យងាយស្រួលក្នុងការអនុវត្តសាលដីកាស្ថាពរ និង ធានាផលប្រយោជន៍គូភាគី តុលាការកំពូលគប្បីធ្វើការបែងចែកដីទំនាស់តាមចំណុចគោល A B C D E F G H I J K L M N ក្នុងប្លង់ទី តាំងដីទំនាស់ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៣ របស់ចៅក្រមតុលាការកំពូល ដោយបន្ទាត់ត្រង់ I J K L ស្រប ជាមួយបន្ទាត់ត្រង់ AHGF និង BCDE ហើយ AI=IB=FL=LE=5,00 ម៉ែត្រ,បន្ទាត់ MC=ND=2,00 ម៉ែត្រ និង CD=HG=10,00 ម៉ែត្រ ។

- យល់ឃើញថា នៅលើដីទំនាស់មានផ្នូរម្តាយរបស់ដើមចោទ ដែលបរិវេណនេះគ្មានជនណាអាច បំពារបំពានបានទេ គប្បីប្រគល់ទីតាំងដីផ្នូរ H J M N K G H ឱ្យទៅដើមចោទកាន់កាប់គ្រប់គ្រង ហើយដីក្រៅ ពីទីតាំងនេះ ត្រូវបែងចែកជាពីរចំណែកស្មើគ្នា តាមមាត្រា៧០នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៩០"គ" ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០១ របស់សាលា ឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តីចំពោះមុខគូភាគី

១- ទទួលបណ្តឹងសាទុក្ខលើកទី២លេខ៤០៨ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០១ របស់លោកអ៊ុច គីម សាន្ត ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ៩០"គ" ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣- សម្រេចបែងចែកដីទំនាស់ ជាពីរចំណែកតាមគំនូសប្លង់ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៣ របស់ចៅក្រមតុលាការកំពូល គឺ :

ក-/ ផ្នែកខាងត្បូងទំហំ A I J M N K L F G H A ត្រូវប្រគល់ឱ្យលោកអ៊ិច គឹមសាន្ត ។

ខ-/ ផ្នែកខាងជើងទំហំ B C D E D E L K N M J I B ត្រូវប្រគល់ឱ្យអ្នកស្រី ជា ឈុនឡាំង។

៤- រឹបអូសប្រាក់ប្រដាប់ក្ដី ចំនួន១៩.០០០រៀល ដែលលោកអ៊ិច គឹមសាន្ត បានបង់រួចហើយ គឺ :

- ពន្ធចុះបញ្ជីក្ដី និង ពន្ធហ្វិងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

- ចំណាយក្នុងកិច្ចប្រគល់ដីការកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀល ហើយតម្រូវឱ្យអ្នកស្រី ជា ឈុនឡាំង សងប្រាក់១៩.០០០រៀលនេះ ទៅដើមចោទវិញ ។

៥- សាលដីកានេះ ជំនុំជំរះនៅថ្ងៃទី១២ ខែមករា ឆ្នាំ២០០៤ និងប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៤ ។